**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តឧត្តរមានជ័យ**
លេខ ០០១ ដី.ក.ខ.ជ

# ដីកា
# ស្តីពី
# ការបង្កើតក្រុមទទួលបន្ទុកព័ត៌មានរដ្ឋបាលខេត្តឧត្តរមានជ័យ

## ប្រធានក្រុមប្រឹក្សាខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ប្រកាសឱ្យប្រើច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៥ចុះថ្ងៃទី ២៨ ខែ មករា ធ្នូឆ្នាំ ១៩៩៥ ស្តីពីការបង្កើតខេត្តឧត្តមានជ័យ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក
- ប្រកាសអន្តរក្រសួង ស្តីពីតួនាទី ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកព័តិមានរដ្ឋបាលរាជធានី ខេត្ត លេខ៣៩២ ប្រក មផ និង លេខ ៤៤៣.ពមប្រក ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១២
- លិខិតលេខ ៣៩១ សជណ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ របស់ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃស្តីពីសំណើតែងតាំងមន្ត្រីទទួលបន្ទុកព័តិមាននៅថ្នាក់រាជធានី ខេត្ត

- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស០៥១៤/៦/រកម/៦៦១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ។
- យោងស្មារតីអង្គប្រជុំរបស់ គណៈអភិបាលខេត្ត ស្តីពីការជ្រើសរើស សមាសភាពជាប្រធាន និងសមាជិកក្រុមមន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្ត នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤
- យោងស្មារតីអង្គប្រជុំវិសាមញ្ញលើកទី២ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមមន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១.លោក | **វ៉ាត ប៉ាវ៉ានីន** | អភិបាលរងខេត្ត | ប្រធាន |
| ២. លោក | **ឃឹម ម៉ុនថន** | ប្រធានមន្ទីរព័ត៌មាន | សមាជិក |
| ៣.លោក | **ហោ ជិនវិរយុទ្ធ** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |

**ប្រការ ២.-**

មន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យគឺជាអ្នកនាំពាក្យរបស់រដ្ឋបាលខេត្ត។ មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវជួយក្រុមប្រឹក្សាខេត្តក្នុងការធានាឱ្យមានការផ្សព្វផ្សាយព័ត៌មានជា សាធារណៈបានកាន់តែទូលំទូលាយ មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ ៣.-**

មន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យមានភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានរបស់រដ្ឋបាលខេត្ត ជូនប្រជាពលរដ្ឋ សាធារណៈជនអ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធនានា
- ធ្វើជាអ្នកសារព័ត៌មាននិងរៀបចំសន្និសីទសារព័ត៌មាននៅថ្នាក់ខេត្ត
- ផ្តល់សេចក្តីសង្ខេបព័ត៌មានដោយផ្ទាល់មាត់ ឬរាយការណ៍តាមទូរស័ព្ទ ឬជាលាយលក្ខអក្សរជូនប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាក្នុងនាមរដ្ឋបាលខេត្ត
- ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្តអំពីការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនសាធារណៈជន និងអ្នកស្នើសុំព័ត៌មាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- រៀបចំឱ្យមានបញ្ជរព័ត៌មាន និងមានមន្ត្រីប្រចាំការសម្រាប់ផ្តល់ព័ត៌មានជូនសាធារណៈជននៅសាលាខេត្ត
- រៀបចំឱ្យមានក្តារព័ត៌មានជាសាធារណៈនៅសាលាខេត្តនិងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្តតាមការចាំបាច់ហើយដែលទីកន្លែងទាំងនោះ មានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈ
- ក្រៅពីក្តារព័ត៌មានត្រូវរៀបចំឱ្យមានមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតដូចជាតាមរយៈគេហទំព័រព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តីរបស់រដ្ឋបាលខេត្ត និងតាមរយៈប្រព័ន្ធឧត្សាសនសព្ទ វិទ្យុ ទូរទស្សន៍ជាដើម
- ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវរាល់ព័ត៌មានដែលបានបិទផ្សាយនៅលើក្តារព័ត៌មាននិងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត
- អនុវត្តតួនាទីផ្សេងទៀតតាមការស្នើសុំរបស់ក្រុមប្រឹក្សាខេត្ត និង គណៈអភិបាលខេត្ត
- រៀបចំប្រមូលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋពីបណ្តាមន្ទីរ ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សារាជធានី ខេត្ត
- ធ្វើការកែតម្រូវរាល់ព័ត៌មាន ដែលមិនត្រឹមត្រូវ

**ប្រការ ៤.-**

ក្រុមទទួលបន្ទុកព័ត៌មានរដ្ឋបាលខេត្ត មានសិទ្ធិ៖

- ប្រើប្រាស់មន្ត្រីក្រោមឱវាទ
- រៀបចំឱ្យមានមន្ត្រីទទួលបន្ទុកព័ត៌មានរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ប្រការ ៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន មន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្តត្រូវ ៖

- អនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន
- បែងចែកតួនាទីជាក់លាក់សម្រាប់សមាជិកម្នាក់ៗក្នុងក្រុមផ្តល់ព័ត៌មានសម្រាប់ការងារផ្សព្វផ្សាយព័ត៌មាន។ ទោះបីជាកិច្ចការមួយចំនួនត្រូវបានបែងចែកឱ្យសមាជិកក្រុមអនុវត្តក៏ដោយ ក៏ប្រធានក្រុមទទួលបន្ទុកផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវនូវរាល់ព័ត៌មានដែលសមាជិកក្រុមបានផ្សព្វផ្សាយ
- ធានាថាព័ត៌មានដែលបានផ្សព្វផ្សាយ គឺជាព័ត៌មានដែលត្រឹមត្រូវ សុក្រឹត្យ និងងាយយល់ពីគ្រប់អ្នកពាក់ព័ន្ធ
- បានទទួលការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពតាមការចាំបាច់

- មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលខេត្តរបស់ខ្លួនអំពីព័ត៌មានដែលបានផ្សព្វផ្សាយ
- រាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាគណៈអភិបាលអំពីការផ្សព្វផ្សាយព័ត៌មានដែលបានអនុវត្ត

**ប្រការ ៦.~**

មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋនិងក្រុមអ្នកសារព័ត៌មាន ឬអ្នកស្នើសុំឱ្យបានលឿនតាមការដែលអាចធ្វើទៅបាន។ ចំពោះការស្នើសុំព័ត៌មានជាលាយលក្ខណ៍អក្សរ មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវចាត់ចែងឆ្លើយតបឱ្យបានលឿននិងមិនត្រូវយឺតជាងសាមសិបថ្ងៃ(៣០ថ្ងៃ)ឡើយ។ ក្នុងករណីមិនឆ្លើយតបតាមការកំណត់ ប្រធានក្រុមប្រឹក្សា ខេត្តឬអភិបាល ខេត្តអាចនឹងធ្វើការស្តីបន្ទោសជាលាយលក្ខណ៍អក្សរដល់ក្រុមទទួលបន្ទុកព័ត៌មាន។ ក្នុងករណីការស្នើសុំព័ត៌មានត្រូវបានបដិសេធទាំងស្រុងឬផ្នែកណាមួយ មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវបង្ហាញឱ្យបានច្បាស់លាស់ និងសមហេតុផលអំពីមូលហេតុនៃការបដិសេធនោះ។

**ប្រការ ៧.~**

មន្ត្រីទទួលបន្ទុកព័ត៌មានមិនត្រូវផ្តល់ព័ត៌មានដល់សាធារណៈជននូវ ៖

- ព័ត៌មានដែលតុលាការបានហាមក្នុងការផ្សព្វផ្សាយជាសាធារណៈ
- ព័ត៌មានសម្ងាត់របស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជំរះក្តី
- សំណុំរឿងដែលស្ថិតនៅក្នុងការស៊ើបសួររបស់តុលាការ
- ព័ត៌មានដែលនាំឱ្យអន្តរាយដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ
- ព័ត៌មានដែលនាំឱ្យអន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ។
- ព័ត៌មានដែលមានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗដោយរួមបញ្ចូលទាំងព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាសុខភាព ព្រមទាំងព័ត៌មានសម្ងាត់ផ្សេងៗទៀត
- ព័ត៌មានដែលអាចនឹងបង្កគ្រោះថ្នាក់ដល់ការបំពេញបេសកកម្មរបស់មន្ត្រីអនុវត្តច្បាប់។
- ព័ត៌មានផ្សេងទៀតដែលបានកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា។

**ប្រការ ៨.~**

គណៈអភិបាលខេត្តត្រូវផ្តល់សម្ភារៈ និងមធ្យោបាយសមស្របគ្រប់គ្រាន់ដើម្បីឱ្យមន្ត្រីទទួលបន្ទុកព័ត៌មានអាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៩.~**

ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវ មន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មានអាចទំនាក់ទំនងដោយផ្ទាល់ជាមួយប្រធានក្រុមប្រឹក្សាខេត្ត អភិបាលខេត្តរបស់ខ្លួន និងជាមួយប្រធានមន្ទីរ អង្គភាពជំនាញនានា

នៅថ្នាក់ខេត្ត។ លើសពីនេះទៀត មន្ត្រីទទួលបន្ទុកព័ត៌មានអាចចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត កិច្ចប្រជុំរបស់គណៈអភិបាលខេត្ត និងកិច្ចប្រជុំផ្សេងទៀតរបស់រដ្ឋបាលខេត្តរបស់ខ្លួន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

**ប្រការ ១០.-**

រដ្ឋបាលខេត្តមន្ទីរ អង្គភាពជុំវិញខេត្តត្រូវសហការ និងផ្ដល់ព័ត៌មានជាក់លាក់ សុក្រឹត្យ និងទាន់ពេលវេលាដល់មន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្ត។

**ប្រការ ១១.-**

មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវបានអនុញ្ញាតិឱ្យផ្ដល់ព័ត៌មានជូនដល់តំណាងប្រព័ន្ធសារព័ត៌មានក្នុងនាមរដ្ឋបាលខេត្ត។ ក្នុងករណីមានការស្នើសុំព័ត៌មានទៅមន្ត្រីចំណុះសាលាខេត្តដែលមិនទទួលបន្ទុកព័ត៌មាន មន្ត្រីទាំងនោះផ្ទេរការទទួលខុសត្រូវក្នុងការឆ្លើយតបទៅមន្ត្រីទទួលបន្ទុកព័ត៌មានជាអ្នកបកស្រាយលើកលែងតែមន្ត្រីទទួលបន្ទុកព័ត៌មាន មិនអាចឆ្លើយបានទើបមន្ត្រីទទួលបន្ទុកព័ត៌មានត្រូវផ្ទេរការទទួលខុសត្រូវនេះទៅមន្ត្រីសាមុីជាអ្នកឆ្លើយតប ។រាល់ការស្នើសុំព័ត៌មានទាំងឡាយណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដទៃឬក្នុងដែនសមត្ថកិច្ចរបស់មន្ត្រីឬស្ថាប័នជាន់ខ្ពស់របស់រាជរដ្ឋាភិបាលក្រុមទទួលបន្ទុកព័ត៌មានត្រូវបញ្ជូនការទទួលខុសត្រូវទៅក្រុមប្រឹក្សា ឬស្ថាប័នសាមីក្នុងការឆ្លើយតប។

**ប្រការ ១២.-**

សេចក្ដីថ្លែងការណ៍របស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ទីរ អង្គភាពជំនាញនៅថ្នាក់ខេត្ត ត្រូវធ្វើឡើងតាមរយៈមន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលខេត្ត។ ក្នុងករណីដែលក្រុមប្រឹក្សា គណៈអភិបាល និងប្រធានមន្ទីរ អង្គភាពជំនាញនៅថ្នាក់ខេត្តមានបំណងធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់ក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬមន្ទីរអង្គភាពជំនាញនីមួយៗនោះត្រូវទំនាក់ទំនង និងសម្របសម្រួលជាមួយមន្ត្រីទទួលបន្ទុកព័ត៌មាន។

**ប្រការ ១៣.-**

សាលាខេត្តមន្ទីរព័ត៌មានខេត្តមន្ទីរ អង្គភាពនានាក្នុងខេត្តនិងមន្ត្រីទទួលបន្ទុកព័ត៌មានត្រូវអនុវត្ត *ដីកា*នេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧត្តរមានជ័យ, ថ្ងៃទី.២៥.ខែ.កក្កដា.ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាខេត្ត**

ញើប_ធិន

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- លេខាធិការដ្ឋាន គ.ជ.អ.ប
- គ្រប់ទីចាត់ការចំណុះសាលារាជធានី ខេត្ត
- មន្ទីរ អង្គភាពនៅថ្នាក់រាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- អ្នកសារព័ត៌មាននៅថ្នាក់រាជធានី ខេត្ត
"ដើម្បីជ្រាប និងសហការ"
-ដូចប្រការ១ "ដើម្បីអនុវត្ត"
-ឯកសារកាលប្បវត្តិ